## ក្រសួងសុខាភិបាល ឡុងប៊ីច យល់ព្រមមកលើគម្រោងបើកសាលារៀន

ជម្រាបជូនសហគមន៍សាលារៀន ឡុងប៊ីច

នៅពេលជិតដល់ពេញមួយឆ្នាំតាំងពីយើងបានបិទសាលារៀន គឺយើងមានសេចក្តីរីករាយប្រកាសដំណឹងល្អជាបន្តបន្ទាប់ខ្លះៗអំពីសាលារៀន និង គម្រោងបើកសាលារៀនរបស់យើង ។ ក្រសួងសុខាភិបាល ឡុងប៊ីច បានយល់ព្រមមកលើគម្រោងបើកសាលារៀនរបស់យើងក្នុងសប្តាហ៍នេះ ដែលធ្វើអោយយើងអាចបញ្ជូនសិស្សពីកម្រិតថ្នាក់ transitional kindergarten ទៅកាន់ថ្នាក់ទី ប្រាំ ត្រឡប់ចូលរៀនវិញបានស្របតាមការគ្រោងទុកមក ដែលផ្តើមនៅថ្ងៃទី29 ខែមិនា ។ មាតាបិតាបានចាប់ផ្តើមទទួលដំណឹងផ្ទាល់រួចមកហើយពីសាលារៀនអំពីគម្រោងប្រើទូទាំងក្រសួងអប់រំ ឌីស្ទ្រីគ សម្រាប់ផ្នែកសុវត្ថិភាព និង អ្វីបន្ថែមយ៉ាងច្បាស់លាស់នៅតាមសាលារៀននិមួយៗ ។

យើងមានសេចក្តីអំណរគុណទៅកាន់ក្រសួងសុខាភិបាល ឡុងប៊ីច ដែលបន្តធ្វើជាដៃគូជាមួយយើងក្នុងគ្រាឆ្លងកាត់មេរោគចម្លងជាពិសេស ការប្រឹងប្រែងចាក់ថ្នាំបង្ការជម្ងឺ ដើម្បីបញ្ជាក់ថា បុគ្គលិករបស់យើងពិតជាមានឱកាសណាត់ជួបមែនសម្រាប់ការចាក់ថ្នាំ ។ សហការណ៍ជារបៀបនេះឯងត្រូវបានទទួលការជាប់ឈ្មោះល្បីល្បាញទូទាំងប្រទេស និង ចាត់ទុកជាគំរូដៃគូរួមមួយ ដែលបាននាំមកជាលទ្ធផលល្អសម្រាប់សុខភាពនៅតាមសហគមន៍ និង សាលារៀនរបស់យើង ។

ការយល់ព្រមពីក្រសួងសុខាភិបាលមកលើគម្រោងរបស់យើង គឺត្រូវបានទទួល នៅពេលមានមនុស្សឆ្លងជម្ងឺជាចំនួន 5.2 ក្នុងចំណោម 100,000 នាក់នៅតាម ឡូស អ៊ែនជេឡេស ខោនធី ក្នុងសប្តាហ៍នេះ ដែលជាសញ្ញាបង្ហាញការបន្តស្រកចុះកាន់តែច្រើនអស់រយៈពេលជាងប៉ុន្មានសប្តាហ៍ថ្មីៗកន្លងមក ។

នៅពេលថ្ងៃទី29 ខែមិនា កាន់តែជិតមកដល់ គឺក្រុមគ្រួសារនៃសិស្សនៅតាមសាលាបឋមសិក្សាគួរបន្តការទាក់ទងជាមួយសាលារៀនរបស់ពួកគេ ដើម្បីទទួលដំណឹងកាន់តែច្បាស់អំពីសាលារៀនរបស់ពួកគេ ទោះបីជាលោកអ្នកបានជ្រើសរើសអោយសិស្សត្រឡប់ចូលរៀនវិញក្តី ឬ ទុកសិស្សអោយរៀនបន្ត អនឡាញ ទាំងស្រុងក្តី ។ ដូចបានលើកបង្ហាញពីសប្តាហ៍កន្លងផុតមកហើយ គឺនេះជាពេលសម្រាប់ជជែកជាមួយសិស្សអំពីការផ្លាស់ប្តូរ ដែលកំពុងកើតឡើងសម្រាប់ពួកគេ ។

គម្រោងបើកសាលារៀននៃក្រសួងអប់រំ ឌីស្ទ្រីគ សម្រាប់សិស្សកម្រិតថ្នាក់ទាំងអស់ក៏ត្រូវបានទទួលការកែសម្រួលផងដែរក្នុងពេលថ្មីៗនេះនៅតាម គម្រោងបើកសាលារៀន និង សុវត្ថិភាព ក្នុងគ្រារាលដាលនៃជម្ងឺ COVID-19 ហើយអាចបើកមើលបាននៅតាម
lbschools.net/coronavirus ។

**អនុវិទ្យាល័យ និង វិទ្យាល័យ**

នៅពេលលទ្ធផលទាក់ទងផ្នែកសុខភាពក្នុងសហគមន៍បន្តការបង្ហាញជាភាពល្អគួរលាស់ គឺឱកាសក៏កាន់តែបង្កើនឡើងសម្រាប់បើកទទួលសិស្សអនុវិទ្យាល័យ និង វិទ្យាល័យត្រឡប់ចូលរៀនវិញតាមរយៈបង្ហាត់កម្មវិធីបញ្ចូលគ្នា ដែលនឹងប្រើថ្ងៃខែដូចតែយើងធ្លាប់បានប្រកាសរួចមកហើយសម្រាប់ក្រុមគ្រួសារទាំងឡាយណា ដែលជ្រើសរើសយកការបង្ហាត់កម្មវិធីជារបៀបនេះ ...

- ថ្ងៃទី19 ខែមេសា - ថ្នាក់ទី 12
- ថ្ងៃទី20 ខែមេសា - ថ្នាក់ទី 6 ទៅ 8
- ថ្ងៃទី26 ខែមេសា - ថ្នាក់ទី 9 ទៅ 11

ដូចអ្វីបានរៀបចំមកនៅតាមសាលាបឋមសិក្សា គឺសព្វថ្ងៃ យើងកំពុងតែធ្វើការស្ទង់វាស់ទៅកាន់មាតាបិតានៃសិស្សអនុវិទ្យាល័យ និង វិទ្យាល័យអំពីចំណង់ចិត្តជ្រើសរើសយកការបង្ហាត់កម្មវិធីសម្រាប់សិស្សរបស់ពួកគាត់ ។ ការស្ទង់វាស់នឹងបិទបញ្ចប់នៅថ្ងៃសុក្រនេះ ត្រូវជាថ្ងៃទី12 ខែមិនា ។ ចំពោះមាតាបិតាទាំងឡាយណា ដែលមិនទាន់បានឆ្លើយបង្ហាញនៅឡើយមកលើការស្ទង់វាស់ គឺនៅមានពេលដល់ទៅថ្ងៃ

សុក្រសម្រាប់ឆ្លើយបង្ហាញនៅក្នុង ParentVue ។ បើលោកអ្នកមានសំនួរអំពីមធ្យោបាយជ្រើសរើសយកការបង្ហាត់កម្មវិធី ឬ ត្រូវការជំនួយឆ្លើយបំពេញមកលើការស្ទង់វាស់ គឺសូមទាក់ទងការិយាល័យសាលារៀនរបស់លោកអ្នក ។

**កម្មវិធីកីឡា និង កម្មវិធីអ្វីផ្សេងៗ**

ក្នុងរយៈពេលថ្មីៗនេះ រដ្ឋ កាលីហ្វ័រញ៉ា បានបង្ហាញជាក្បួនណែនាំផ្សេងៗសម្រាប់កម្មវិធីប្រកួតកីឡា ដូចជាៈ ហ៊ូតប៊ូល បេ៊សប៊ូល ស៊ូហ្វប៊ូល បាល់ទាត់ បាល់គ្រវែងហែលទឹក និង កម្មវិធីកីឡាផ្សេងៗទៀត ដែលត្រកួតតាមទីវាលក្រៅ អោយត្រឡប់ចូលហាត់វិញ នៅពេលណាមានឪកាសសម្រាប់បំពេញស្របតាមលក្ខណបាន ។ មានកម្មវិធីកីឡាខ្លះបានចាប់ផ្តើមរួចទៅហើយ ហើយកម្មវិធីកីឡាផ្សេងៗទៀតកំពុងតែត្រៀមទុក ។ សូមរង់ចាំទទួលដំណឹងបន្ថែមពីសាលារៀន ។

នៅពេលយើងកំពុងធ្វើការសង្កត់មកលើសុវត្ថិភាពសម្រាប់បើកសាលារៀនឡើងវិញ គឺក្រុមរបស់យើងក៏កំពុងតែរៀបជាគម្រោងផងដែរ សម្រាប់ឆ្នាំសិក្សាថ្មី ។ យើងសង្ឃឹមថា នឹងផ្តល់ជាការជ្រើសរើសទៅកាន់ក្រុមគ្រួសារបានអំពីកម្មវិធីបង្ហាត់ពេញថ្ងៃក្នុងសាលារៀន ឬ កម្មវិធីរៀន អនឡាញ ទាំងស្រុងនៅតាមផ្ទះ ។ យើងនឹងជម្រាបជូនកាន់តែច្បាស់នៅពេលណាបានទទួលដំណឹងបន្ថែម ។

សូមអរគុណចំពោះក្រុមគ្រួសារ និង បុគ្គលិករបស់យើងទាំងអស់ដោយបានជួយគាំទ្រក្នុងគ្រាមួយដ៏សែនលំបាក ប៉ុន្តែ ក៏លាយជាមួយគ្រាមួយពោរពេញដោយសេចក្តីសង្ឃឹមផងដែរ នៅពេលយើងរង់ចាំទទួលសិស្សជាច្រើននាក់ត្រឡប់ចូលសាលារៀនវិញយ៉ាងឆាប់រហ័ស ។

ដោយសេចក្តីស្មោះ,

Jill

Jill Baker, Ed. D.
អគ្គនាយកសាលារៀន